# សេចក្តីអំពាវនាវ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ចំពោះរាជរដ្ឋាភិបាលខ្មែរ និងអង្គការសហប្រជាជាតិ
## សូមប្រមូលមេខ្មែរក្រហមជាន់ខ្ពស់ដែលមានមុខសញ្ញា
## ត្រូវកាត់ទោសដាក់នៅទីសុវត្ថិភាពមួយកន្លែង

web site: hoksavann.org

សូមអំពាវនាវចំពោះរាជរដ្ឋាភិបាលខ្មែរ និងអង្គការសហប្រជាជាតិ បើចង់កាត់ទោសខ្មែរក្រហម ដែលបានសម្លាប់ប្រជាពលរដ្ឋខ្មែររាប់លាននាក់ ដើម្បីរកយុត្តិធម៌ជូនអ្នករងគ្រោះទាំងនោះពិតមែន សូមប្រមូលមេខ្មែរក្រហមជាកម្មាភិបាលជាន់ខ្ពស់ ដែលមានមុខសញ្ញាត្រូវកាត់ទោស ដាក់នៅទីសុវត្ថិភាពមួយកន្លែង ។ ការយកមេខ្មែរក្រហមទាំងនោះ ដាក់ក្នុងទីសុវត្ថិភាពនេះ ពុំមែនដាក់ក្នុងពន្ធនាគារធ្វើទោស ឬដាក់ឃុំទេ តែដើម្បីរក្សាសន្តិសុខជូនខ្មែរក្រហមទាំងនោះ នៅពេលកាត់ទោសជិតមកដល់ ដោយផ្តល់ទីស្នាក់នៅសមរម្យ ចំណីអាហារគ្រប់គ្រាន់ បើមានជម្ងឺត្រូវមានវេជ្ជបណ្ឌិតរបស់អង្គការសហប្រជាជាតិ ឬវេជ្ជបណ្ឌិតរបស់អង្គការក្រៅរដ្ឋាភិបាលខ្មែរទៅព្យាបាល ។ វិធានការនេះ គឺដើម្បីការពារមេខ្មែរក្រហមទាំងនោះ កុំឲ្យទទួលគ្រោះថ្នាក់បែបណាមួយ រហូតស្លាប់មិនប្រក្រតី នៅពេលការកាត់ទោសជិតមកដល់ ដោយសារអ្នកនៅពីក្រោយ មិនចង់ឲ្យឆ្លើយនៅក្នុងតុលាការ ព្រោះបញ្ហាការកាប់សម្លាប់នេះ មានពាក់ព័ន្ធជាមួយគេក្នុងចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ដូចករណីការស្លាប់មិនប្រក្រតីរបស់មេខ្មែរក្រហមប៉ុល-ពត គឺគាត់ស្លាប់បន្ទាប់ពីដំណឹងថា អង្គការសហប្រជាជាតិមានសហរដ្ឋអាមេរិកជាដើម មានបំណងជំរុញឲ្យមានការកាត់ទោសមេខ្មែរក្រហម មានប៉ុល-ពតជាដើម ។ ពិភពលោកទាំងមូលបានដឹងហើយថា សាធារណរដ្ឋប្រជាមានិតចិន គឺចិនកុម្មុយនិស្តនេះហើយ ដែលគាំទ្រនឹងផ្តល់សម្ភារៈសឹកគ្រប់បែបយ៉ាងដល់ខ្មែរក្រហម តាំងពីសង្គ្រាម៥ឆ្នាំ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ។ ពេលដែលខ្មែរក្រហមឡើងកាន់អំណាច ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ចិនកុម្មុយនិស្តបានបញ្ជូនទីប្រឹក្សានិងអ្នកបច្ចេកទេសស្ទើរគ្រប់ផ្នែក ជួយឧបត្ថម្ភខ្មែរក្រហម ។ ប៉ុន្តែមានមតិមួយទៀតពោលថា ការស្លាប់របស់ប្រជាពលរដ្ឋខ្មែររាប់លាន

នាក់នេះ ពុំមែនខ្មែរនិងខ្មែរសម្លាប់គ្នាទេ គឺស្លាប់ដោយសារចារកិច្ចវៀតណាមបង្កប់ខ្លួន ដូចជាសៀវភៅដែលមានចំណងជើងថា «អង្គការជានរណា» ដែលសរសេរដោយយាយទៀងនិយាយថា អង្គការគឺវៀតណាម ។ ដូច្នេះដើម្បីឲ្យដឹងការពិតបែបណានោះ ត្រូវតែថែរក្សាសុខភាពនិងសុវត្ថិភាពរបស់ខ្មែរក្រហមជាន់ខ្ពស់តាំងនេះ ដើម្បីឲ្យបានឆ្លើយក្នុងតុលាការចំរុះ រវាងខ្មែរនិងអង្គការសហប្រជាជាតិ ដែលនឹងកើតមានក្នុងពេលខាងមុខនេះ ។

ព្រះពុទ្ធសាសនាបានបង្រៀនថា កុំឲ្យមនុស្សចងពៀរគ្នា ប៉ុន្តែចំពោះពុទ្ធសាសនិកជនខ្មែរ ដែលយល់ស្របឲ្យមានការការកាត់ទោសមេខ្មែរក្រហមទាំងនោះ ពុំមែនបានន័យថា ចងពៀរជាមួយខ្មែរក្រហមឡើយ ប៉ុន្តែមានបំណងចង់រកយុត្តិធម៌ជូនអ្នករងគ្រោះស្លាប់រាប់លាននាក់ និងអ្នកនៅរស់ទទួលការឈឺចាប់ព្រាត់ប្រាស់គ្រួសារប៉ុណ្ណោះ ដូចជាព្រះសង្ឃព្រះពុទ្ធសាសនាបានប្រព្រឹត្តខុសព្រះវិន័យសង្ឃ ព្រះវិន័យធម៌ ក៏វិនិច្ឆ័យទោសរបស់ព្រះសង្ឃអង្គនោះ ទៅតាមកំហុសមានលក្ខណៈដូចនេះដែរ ។

មានការបារម្ភថា មេខ្មែរក្រហមទាំងនោះអាចស្លាប់មិនប្រក្រតីដូចប៉ុល-ពត ឬរត់គេចខ្លួនទៅទីណាមួយ ព្រោះបញ្ហាខ្មែរក្រហមនេះ ពុំមែនជាបញ្ហាធម្មតាទេ ជាបញ្ហាអន្តរជាតិ គឺជាទោសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយពាក់ព័ន្ធជាមួយនយោបាយរបស់អ្នកនៅពីក្រោយខ្នងផង ។ ដូចប៉ុល-ពតដែរ គ្រាន់តែតុលាការចំរុះរៀបចំការកាត់ទោស អៀង-សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរក្រហម តាមដំណឹងពិតឬពុំពិតបែបណាថា អៀង-សារីបានគេចខ្លួនទៅព្យាបាលរោគនៅប្រទេសថៃ ។ គួរកត់សំគាល់ថា អៀង-សារីនេះជាតួអង្គសំខាន់ណាស់របស់ខ្មែរក្រហម ដែលដឹងការពិតនៃកិច្ចការផ្ទៃក្នុង និងកិច្ចការបរទេសរបស់ខ្មែរក្រហម ជាពិសេសតែងតែមានទំនាក់ទំនងជាមួយសាធារណរដ្ឋចិនប្រជាមានិតុក្នុងនាមប៉ុល-ពត ។ ដូច្នេះអៀង-សារីទៅបេទ្យឬមិនទៅពេទ្យ គាត់នៅរស់ឬនឹងស្លាប់ តាមប្រក្រតីឬមិនតាមប្រក្រតី ត្រូវស្ថិតនៅក្នុងការសង្ស័យ ព្រោះអៀង-សារីមានអ្នកធំស្ថិតនៅពីក្រោយ សូម្បីថៃក៏មានការជិតស្និទ្ធជាមួយកុម្មុយនិស្តចិនដែរ ។

នៅទីបំផុតនេះ បើចង់កាត់ទោសខ្មែរក្រហមពិតមែន សូមរាជរដ្ឋាភិបាលខ្មែរនិងអង្គការសហប្រជាជាតិ ប្រមូលមេខ្មែរក្រហម ដូចជាអៀង-សារី, អៀង-ធីរិទ្ធ, នួន-ជា, ខៀវ-សំផនជាដើម ដាក់នៅទីសុវត្ថិភាពមួយកន្លែង ដើម្បីការពារសន្តិសុខជូនគាត់ កុំឲ្យមានវិបត្តិអ្វីមួយមុនកាត់ទោស និងមុនមេធាវីធ្វើការចោទប្រកាន់ ។ បើមិនដូច្នោះទេ តុលាការហៅសួរចម្លើយបានតែកម្មាភិបាលថ្នាក់ក្រោម ដូចយ៉ាងតាម៉ុកនិងនាយឌុច ដែលកំពុងជាប់ឃុំសព្វថ្ងៃនេះ ដែលធ្វើឲ្យថវិកាជាង៦០លានដុល្លារ ដែលត្រូវចំណាយក្នុងការកាត់ទោសនេះ ទៅជាឥតន័យ ដោយពុំអាចរកយុត្តិធម៌ជូនអ្នករងគ្រោះខ្មែរបានពិតប្រាកដ ។

វត្តខ្មែរកាណាដា, ថ្ងៃទី១ មីនា ២០០៦

ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ